# **របាយការណ៍សិក្ខាសាលា**

**សូមគោរព ......**

ខ្ញុំបាទ សូមអនុញ្ញាតិសង្ខេបជូនឯកឧត្តមគណៈធិបតិ និងសមាជិក សមាជិកា អង្គសិក្ខាសាលា អំពីលទ្ធផលនៃអង្គសិក្ខាសាលារយៈពេលពីរថ្ងៃ ដូចខាងក្រោម .......

**១) អ្នកចូលរួម**

ប្រការដែលគួរសោមនស្សរីករាយបំផុតរបស់សិក្ខាសាលានេះ គឺទទួលបានការចាប់អារម្មណ៍ និងបានមកចូលរួមយ៉ាងច្រើនពីអ្នកពាក់ព័ន្ធទាំងអស់ លើសពីផែនការគ្រោងទុក ព្រោះថា យើងគ្រោង តែ ១៦២នាក់ ជាក់ស្តែងមានសមាជិកមកចូលរួមរហូតដល់ទៅ១៩៩នាក់ ជាពិសេសអង្គការសង្គមស៊ីវិល និងដៃគូអភិវឌ្ឍ ដែលចាប់អារម្មណ៍និងស្នើសុំចូលរួមលើសពីការរំពឹងទុក។ ក្នុងនោះ

១. ថ្នាក់ឃុំ៖ មេឃុំ (១១នាក់) ប្រធានមណ្ឌលសុខភាព (១១នាក់) នាយកសាលាបឋមសិក្សា (១១នាក់) សរុបចំនួន **៣៣នាក់**។

២. ថ្នាក់ស្រុក៖ គណៈអភិបាលស្រុក(២១នាក់)នាយករដ្ឋបាលស្រុក(១៩នាក់) ទីប្រឹក្សាស្រុក(១២នាក់) និង តំណាងការិយាល័យអប់រំ យុវជន និងកីឡា (១១នាក់) តំណាងការិយាល័យស្រុកប្រតិបត្តិ(១១នាក់) សរុបចំនួន**៧៤នាក់** ។

៣. ថ្នាក់ខេត្ត៖ ទីប្រឹក្សាគ្រប់គ្រងកម្មវិធីជាតិថ្នាក់ខេត្តនិងទីប្រឹក្សាពង្រឹងសមត្ថភាពខេត្ត (១៣នាក់) ប្រធានមន្ទីរសុខាភិបាលខេត្ត(៣នាក់)និងប្រធានមន្ទីរអប់រំ យុវជន និងកីឡា (០៨នាក់) **សរុបចំនួន២៤នាក់** ។

៤. ថ្នាក់ជាតិ៖ លេខាធិការដ្ឋានគ.ជ.អ.ប (២១នាក់) តំណាងក្រសួងមហាផ្ទៃ (១នាក់) ក្រសួងអប់រំយុវជន និងកីឡា (១នាក់) ក្រសួងសុខាភិបាល (១នាក់) គម្រោង DFGG (១នាក់)**សរុប២៥នាក់**។

៥. សង្គមស៊ីវិល៖ PACT Cambodia (២នាក់) STAR Kampuchea (២នាក់) , WVC (៦នាក់) Save the Children (៩នាក់) RACHA (៤នាក់) API (១នាក់) MLT (២នាក់) CDRI (១នាក់) CCC (១នាក់) PNKS (១នាក់) CORD (២នាក់) Child Fund (១នាក់) និង VSO (១នាក់) **សរុប ៣៣នាក់**។

៦. ដៃគូអភិវឌ្ឍ៖ តំណាងអង្គការ UNICEF (៤នាក់) អង្គការ Sida (១នាក់) EU (១នាក់) USAID (២នាក់) UNFPA (១នាក់) Australian Embassy/DFAT (១នាក់) និងសរុប **ចំនួន១០នាក់**។

## ២) កិច្ចដំណើរការ

អង្គសិក្ខាសាលាមានកិត្តិយស ដោយបាន **ឯកឧត្តម ងី ច័ន្ទ្រផល** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ ចូលរួមថ្លែងសុន្ទរកថាបើកសិក្ខាសាលា និងពន្យល់ដល់សមាជិក សមាជិកា អំពីការវិវត្តរីកចម្រើននៃកិច្ចដំណើរការកំណែទម្រង់រដ្ឋបាលមូលដ្ឋានរបស់ប្រទេសកម្ពុជា និងចំនុចគន្លឹះនៃគោលនយោបាយរបស់រាជរដ្ឋាភិបាល។

បន្ទាប់ពីពិធីបើកសិក្ខាសាលា សមាជិក សមាជិកាទាំងអស់បានស្តាប់បទបង្ហាញ ជាបន្តបន្ទាប់ ដូចខាងក្រោម៖

1. បទបង្ហាញអំពីវឌ្ឍនភាព បញ្ហាប្រឈម និងយោបល់កែលម្អនានា ក្នុងការអនុវត្តផែនការសកម្មភាពគណនេយ្យភាពសង្គមក្នុងឆ្នាំ២០១៤ ដែលបង្ហាញដោយ ខ្ញុំបាទផ្ទាល់។
2. បទបង្ហាញអំពីបទពិសោធន៍ផ្ទាល់ពីការអនុវត្តការងារគណនេយ្យភាពសង្គម ការរៀបចំបិទផ្សាយព័តមាននានា និងព័តមានអំពីថវិកានៅស្រុកក្រឡាញ់ខេត្តសៀមរាប ដែលបង្ហាញដោយលោក ម៉ក់ ប៊ុនចាន់អភិបាលរងស្រុកក្រឡាញ់ខេត្តសៀមរាប ។
3. បទបង្ហាញអំពី បទបង្ហាញអំពីបទពិសោធន៍ផ្ទាល់ពីការអនុវត្តការងារគណនេយ្យភាពសង្គម ការរៀបចំបិទផ្សាយព័តមាននានា និងព័តមានអំពីថវិកានៅឃុំស្រែសង្គមស្រុកកោះញែក ខេត្តមណ្ឌលគីរី បង្ហាញដោយ លោក កែវ ទីណង់ មេឃុំស្រែសង្គម ស្រុកកោះញែកខេត្តមណ្ឌលគិរី ។
4. បទបង្ហាញរបស់តំណាងអង្គការPact ស្តីពីបទពិសោធន៍ពាក់ព័ន្ធការជ្រើសរើសនិង បណ្តុះបណ្តាលCAF ការរៀបចំកិច្ចប្រជុំដំបូង ការរៀបចំប័ណ្ណដាក់ពិន្ទុ ការប្រជុំចាត់អាទិភាព ការរៀបចំផ.ស.គ.រ និងការតាមដានការអនុវត្ត ព្រមទាំងបញ្ហាប្រឈមនិងចំនុចត្រូវកែលម្អមួយចំនួន ។
5. បទបង្ហាញរបស់តំណាងអង្គការWorld Vision ស្តីពីប្រវត្តិនៃការអនុវត្តគណនេយ្យភាពសង្គមនៅកម្ពុជា ការអនុវត្តគណនេយ្យភាពសង្គមឆ្នាំ២០១៤ បញ្ហាប្រឈម មេរៀនបទពិសោធន៍ និងរបកគំហើញមួយចំនួន និងផែនការបន្តនៅឆ្នាំ២០១៥-២០១៧។
6. ការពិភាក្សាទូទៅជុំវិញបទពិសោធន៍ និងបញ្ហាប្រឈមនៃ ការអនុវត្តគណនេយ្យភាពសង្គមក្នុងឆ្នាំ២០១៤ ដែលសម្របសម្រួលដោយ តំណាងអង្គការ Save the Children និង អង្គការStar Kampuchea។

បន្ទាប់ពីការបង្ហាញនីមួយៗ មានការសាកសួរបន្ថែមពីសមាជិកសមាជិកា អង្គសិក្ខាសាលា ដែលផ្តោតទៅលើបញ្ហា៖

- កង្វះខាតលិខិតបទដ្ឋានមួយចំនួនទៀត សម្រាប់ណែនាំការអនុវត្ត ពីថ្នាក់ជាតិ ដល់ថ្នាក់ក្រោមជាតិ ដូចជាៈ
    - ការរៀបចំគណកម្មការ ត្រួតពិនិត្យផែនការសកម្មភាពគណនេយ្យភាពរួម ដែលតម្រូវឱ្យមាន ការអនុវត្តឱ្យបានដូចៗគ្នា រវាងដៃគូរអនុវត្ត និងរដ្ឋបាលមូលដ្ឋាន ដើម្បីអនុវត្តបានស្របគ្នា។
    - ខ្វះខាតការរៀបចំយន្តការ ផ្សារភ្ជាប់រវាង ស្រុក ឃុំ ជាមួយថ្នាក់ខេត្ត ។ ជាពិសេសហាក់មានតម្រូវការ បន្ថែមលក្ខខ័ណ្ឌការងារដល់ទីប្រឹក្សាគ្រប់គ្រងកម្មវិធីជាតិថ្នាក់ខេត្ត ឱ្យជួយសម្របសម្រួលការងារគណនេយ្យភាពសង្គមនៅឆ្នាំ២០១៥។
    - គោលការណ៍ ណែនាំបន្ថែម ចំពោះមណ្ឌលសុខភាព និងសាលាបឋមសិក្សា ដើម្បីផ្តល់ មានព័ត៌មានច្បាស់លាស់ពីថវិកាគ្រោង និងចំណាយជាក់ស្តែង។
- ការបិទផ្សាយព័ត៌មានអំពីស្តង់ដារការងារ និងសេវានៃវិស័យទាំងបីអនុវត្តបាន២៧%នៃឃុំគោលដៅសរុប១៨៦។
- ដំណើរការដាក់ពិន្ទុ និងការរៀបចំផែនការសកម្មភាពរួមមិនទាន់បានបន្សីគ្នាទៅនឹងប្រព័ន្ធដែលមានស្រាប់នៅថ្នាក់ឃុំ ស្រុក ដូចជា CIP DIP ។ល។
- យន្តការសម្របសម្រួលជាមួយដៃគូរផ្តល់ជំនួយ ដែលគាំទ្រអង្គការសង្គមស៊ីវិល ហាក់មិនទាន់ច្បាស់លាស់ និងយូរអង្វែង ដែលធ្វើឱ្យលេខាធិការដ្ឋានគ.ជ.អ.ប ពិបាកកំណត់តំបន់គោលដៅអនុវត្ត និងធ្វើការគាំទ្របានជាក់លាក់ ជាពិសេសការពង្រឹងសមត្ថភាព។
- ការធានានិរន្តរភាពនៃការអនុវត្តសកម្មភាពគណនេយ្យភាពសង្គមទៅថ្ងៃអនាគត។
- ការយល់ដឹងអំពីដំណើរការ និងពង្រឹងសមត្ថភាព ទាំងផ្នែកផ្គត់ផ្គង់និងផ្នែកតម្រូវការ នៅតែជាបញ្ហាអាទិភាព ក្នុងឆ្នាំ២០១៥ និងឆ្នាំបន្តបន្ទាប់ទៀត។

នៅថ្ងៃទី២ អង្គសិក្ខាសាលា បានអនុវត្តការពិភាក្សាជាក្រុមតាមបែបWorld Café ដើម្បីស្រង់យកយោបល់និងបទពិសោធន៍នៃការអនុវត្តគណនេយ្យភាពសង្គមនៅមូលដ្ឋាន ទៅតាមសំណួរនាំមុខចំនួន១៦សំណួរ ដែលពាក់ព័ន្ធទៅនឹង និរន្តរភាពនៃការអនុវត្ត លទ្ធភាពពង្រីកការអនុវត្តសកម្មភាពទៅកាន់ស្រុកថ្មី ប្រធានបទឬជំនាញដែលគួរបន្តឬបន្ថែមការបណ្តុះបណ្តាល ការគាំទ្រនានាដែលចាំបាច់ ដំណោះស្រាយដែលអាចអនុវត្ត បានក្នុងករណីគ្មានការគាំទ្រពីដៃគូអង្គការសង្គមស៊ីវិល យោបល់ទៅលើការប្រមូលទិន្នន័យ យោបល់ទៅលើការផ្សព្វផ្សាយព័ត៌មាន ការជម្រុញដំណើរត្រួតពិនិត្យរបស់ប្រជាពលរដ្ឋ និងការអនុវត្តផ.ស.គ.រ និងប្រព័ន្ធM&E សម្រាប់គណនេយ្យភាពសង្គម។

ក្រោយការពិភាក្សាជាក្រុម សមាជិកសមាជិកានៃអង្គសិក្ខាសាលា បានបោះឆ្នោតចំពោះយោបល់ណាដែលល្អជាងគេ។  លទ្ធផលនៃការបោះឆ្នោត  បានបង្ហាញថាចំណុចគន្លឹះចំនួន១៦សម្រាប់យកទៅរៀបចំអនុវត្ត ដែលទទួលសម្លេងគាំទ្រច្រើនបំផុត រួមមាន៖

១- ត្រូវមានការគាំទ្រពីស្ថាប័នជំនាញគ្រប់លំដាប់ថ្នាក់ ឧ. ផ្នែករដ្ឋបាល (ការចេញលិខិតបទដ្ឋានសេចក្ដីណែនាំនានា) និងការគាំទ្រធនធាន ដូចជាធនធានមនុស្ស ថវិកា បច្ចេកទេស សម្ភារៈ។

២- រៀបចំវគ្គបណ្ដុះបណ្ដាល បន្តដល់ក្រុមប្រឹក្សាឃុំ ស្រុក មណ្ឌលសុខភាព ការិយាល័យអប់រំស្រុក សាលាបឋមសិក្សា  ស្ដីពីទស្សនៈទានគណនេយ្យភាពសង្គម  ការបំពេញទិន្នន័យ  ការផ្សព្វផ្សាយកញ្ចប់ព័ត៌មាន ។

៣- រៀបចំវគ្គTOT លើជំនាញសម្របសម្រួល បណ្ដុះបណ្ដាល ហ្វឹកហ្វឺន កិច្ចប្រជុំមានប្រសិទ្ធភាព រៀបចំទស្សនៈកិច្ចសិក្សា

៤- បង្កើតក្រុមការងារគណនេយ្យភាពសង្គមថ្នាក់ខេត្ត ដែលមានសមាសភាពពី មន្ទីរអប់រំ មន្ទីរសុខាភិបាល ទីចាត់ការវិនិយោគនិងផែនការ ទីចាត់ការអន្តរវិស័យ និងអង្គការដៃគូ។

៥- គាំទ្រថវិកាស្រុក ឃុំ និងសម្ភារៈមធ្យោបាយ ។

៦- ថ្នាក់ជាតិផ្ដល់ថវិកាបន្ថែម សម្រាប់អនុវត្តការដាក់ពិន្ទុ។

៧- កំណត់ពេលវេលាឱ្យបានច្បាស់លាស់ ក្នុងការប្រមូលនិងបញ្ជូនទិន្នន័យ។

៨- បញ្ចូលការងារផ្សព្វផ្សាយព័ត៌មាននេះ ទៅក្នុងរបៀបវារៈប្រជុំសាមញ្ញរបស់ ឃុំ ស្រុក និងខេត្ត

៩- រៀបចំកិច្ចប្រជុំប្រចាំត្រីមាសរវាង ខេត្ត ស្រុក ឃុំ ការិយាល័យសុខាភិបាល ការិយាល័យអប់រំជាមួយអង្គការដៃគូ និងអ្នកពាក់ព័ន្ធទាំងអស់។

១០-ផ្សព្វផ្សាយឱ្យបានទូលំទូលាយតាមរយៈមេគូមិ ដោយប្រាប់ពីគោលបំណង របៀបវារៈ

១១- រៀបចំសិក្ខាសាលាផ្សព្វផ្សាយ របាយការណ៍ព័ត៌មានអំពីប័ណ្ណដាក់ពិន្ទុ និងផ.ស.គ.រ នៅថ្នាក់ក្រោមជាតិ និងថ្នាក់ជាតិ ។ សារសំខាន់នៃប័ណ្ណដាក់ពិន្ទុ គឺរៀបចំផែនការទៅតាមតម្រូវការជាក់ស្តែង របស់អ្នកទទួលសេវា

១២- ដាក់បញ្ចូលសកម្មភាពអាទិភាព (លទ្ធផលបោះឆ្នោត) ចូលទៅក្នុងផែនការគណនេយ្យភាពរួម (JAAP) ដែលមានកំណត់ធនធានខាងក្នុង ខាងក្រៅច្បាស់លាស់។

១៣-ជម្រុញការដាក់បញ្ចូល ផែនការសកម្មភាពគណនេយ្យភាពរួម ទៅក្នុងកម្មវិធីវិនិយោគឃុំសង្កាត់។

១៤-គួរកំណត់ស្តង់ដាលើប្រាក់ឧបត្ថម្ភ អ្នកចូលរួម ជាស្ថាប័នរដ្ឋ និងសង្គមស៊ីវិល។

១៥- ថវិកាត្រូវមានខ្ទង់ច្បាស់លាស់ សម្រាប់គណនេយ្យភាពសង្គម។

១៦- ត្រូវរៀបចំសិក្ខាសាលាឆ្លុះបញ្ចាំងប្រចាំឆ្នាំ។

នៅរសៀលថ្ងៃដដែល អង្គសិក្ខាសាលា បានស្តាប់បង្ហាញចំនួនមួយ ស្តីអំពីផែនការអនុវត្តសកម្មភាពគណនេយ្យភាពសង្គមក្នុងឆ្នាំ២០១៥ ទាំងផ្នែកផ្គត់ផ្គង់ និងផ្នែកតម្រូវការ បង្ហាញដោយ លោក លី យ៉ាសាក់ មន្ត្រីតាមដាននិងវាយតម្លៃ នៃលេខាធិការដ្ឋានគ.ជ.អ.ប។

សេចក្តីដូចបានជម្រាបជូនខាងលើនេះ សូមឯកឧត្តមគណាធិបតី សមាជិក សមាជិកា នៃអង្គសិក្ខាសាលាជ្រាបជារបាយការណ៍ និងសូមឯកឧត្តម ផ្តល់អនុសាសន៍ណែនាំតាមការគួរ។

សូមអរគុណ